ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣១

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩

សាលដីកា

លេខ ៧៨ "III"

ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រមរបាយការណ៍

៥-លោក [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ៤៤៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារី ដែលប្ដឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ៩៩ ក្រVI "ប.ស" ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] សារី ភេទប្រុស អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង បច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រៃវែង មុខរបររកស៊ីធ្វើស្រែ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០៤នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ)។ (អ្នកប្ដឹងសាទុក្ខ)

Scanned with CamScanner

ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិប្រស្រែលិច ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

**-ដើមបណ្ដឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ជាត ភេទប្រុស អាយុ៤៥ឆ្នាំ ទីលំនៅភូមិ [redacted] ខេត្តព្រៃវែង ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ នៅភូមិប្រស្រែលិច ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ប្រហែលជាម៉ោង១៧H ឈ្មោះ [redacted] សារិ បានត្រឡប់មកពីផឹកស្រានៅផ្ទះឈ្មោះ [redacted] ធី មកដល់ក៏ដេកលើអង្រឹងក្រោមផ្ទះ ហើយស្រែកឡូឡា ដោយមានអារម្មណ៍ខឹងឈ្មោះ [redacted] វុន ភេទស្រី ត្រូវជាបងថ្លៃដែលធ្លាប់មានទំនាស់ពាក្យសំដីគ្នា កាលពីថ្ងៃមុន ហើយក៏ស្ទុះក្រោកពីអង្រឹងដើរទៅយកចបកាប់ដែលនៅក្បែរនោះ រួចក៏ដើរចូលទៅក្នុងដីភូមិរបស់ឈ្មោះ [redacted] វុន ដែលនៅជាប់គ្នា ពេលនោះមិនឃើញឈ្មោះ [redacted] វុន ទេ ឃើញតែឈ្មោះ [redacted] ទិត ត្រូវជាកូនប្រសារ [redacted] វុន ហើយត្រូវជាក្មួយប្រសារ [redacted] សារី ក្នុងពេលនោះឈ្មោះ [redacted] សារី បានដើរលបពីក្រោយវាយទៅលើឈ្មោះ [redacted] ទិត ដែលកំពុងឈរនៅក្បែរជណ្ដើរ ត្រូវចំក្បាលដួលផ្កាប់មុខទៅលើដីបណ្ដាលឱ្យរបួស ក្រោយពីបានវាយហើយឈ្មោះ [redacted] សារី បានរត់ចូលមកក្នុងដីភូមិរបស់ខ្លួនវិញហើយក៏បោះចបចោល រួចរត់ចូលផ្ទះកូនរបស់ខ្លួន ហើយត្រូវបានសមត្ថកិច្ចតាមហៅឃាត់ខ្លួន ហើយកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តព្រៃវែង ។

-បានឃើញ សាលក្រមលេខ២៧ "គ" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រៃវែងដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ផ្ដន្ទាទោសលើឈ្មោះ [redacted] សារី ភេទប្រុស អាយុ៦៤ឆ្នាំ (មានសាវតាជាតិដូចខាងលើ) កំណត់រយៈពេល០២ឆ្នាំ ដោយអនុវត្តទោសគុក ០១ឆ្នាំ ទោសដែលនៅសល់ព្យួរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិប្រស្រែលិច ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ តាមមាត្រា២១៨ មាត្រា១០៦ មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] សារី ប្រគល់ប្រាក់ថ្លៃព្យាបាល និងជំងឺចិត្តឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៦.០០០.០០០៛(ដប់ប្រាំមួយលានរៀល) នៅពេលសាលក្រមនេះចូលជាស្ថាពរ ការទាមទារលើសពីនេះលើកចោល ។

៣-វត្ថុតាងដែលមានដូចក្នុងកំណត់ហេតុទទួលរបស់តំណាងមហាអយ្យការ ត្រូវរឹបអូសបំផ្លាញចោល។

៤-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងជនជាប់ចោទ ។

-ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ៣១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សារី ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៧ “គ” ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រៃវែងត្រង់ចំណុចទី២ លើសំណងចំនួន១៦លានរៀល ។ ក្រៅពីនេះមិនប្ដឹងទេ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ៣២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ផាត និងឈ្មោះ [redacted] សុទិត ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៧ “គ” ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាលេខ៣៨ ក្រV “ប.ស” ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ៣១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់។

២-ទទួលបណ្ដឹងឧទ្ធរណ៍លេខ៣២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ផាត និងឈ្មោះ [redacted] សុទិត ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៧ “គ” ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ លើកលែងចំណុចទី២ ទាក់ទងនិងសំណងត្រូវកែប្រែពី១៦.០០០.០០០៛(ដប់ប្រាំមួយលានរៀល) ទៅ៤០.០០០.០០០៛ (សែសិបលានរៀល) ឱ្យទៅឈ្មោះ [redacted] សុទិត វិញ ។ ចំណុចផ្សេងពីនេះរក្សាទុកដដែល ។

-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារី ចំពោះមុខឈ្មោះ [redacted] ផាត និងឈ្មោះ [redacted] សុទិត និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ បើកសិទ្ធិប្ដឹងតវ៉ា តាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងទាស់លេខ៣៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារី ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៣៨ ក្រV “ប.ស” ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាលេខ៩៩ ក្រVI “ប.ស” ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ប្រកាសថា បណ្ដឹងទាស់លេខ៣៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារី មិនអាចទទួលយកបាន ។

. សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំពោះឈ្មោះ [redacted] សារី មេធាវីការពារ កំបាំងមុខឈ្មោះ [redacted] ផាត ចំពោះមុខមេធាវី ។

បើកសិទ្ធិប្ដឹងសាទុក្ខតាមច្បាប់ ។

Scanned with CamScanner

-បានឃើញ បណ្តឹងសាទុក្ខលេខ៤៤៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]សារី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៩៩ ក្រVI "ប.ស" ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថាសាលាឧទ្ធរណ៍បានសម្រេចប្រកាសថាបណ្តឹងទាស់លេខ៣៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]សារី មិនអាចទទួលយកបានគឺត្រឹមត្រូវ តាមច្បាប់ហើយ ។ ដូចដែលសាលាឧទ្ធរណ៍បានបង្ហាញស្រាប់នៅក្នុងចំណុចទី៤ សំអាងហេតុនៃសាលដីកា ។ ហើយម្យ៉ាងទៀត ក្នុងមាត្រា៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃ តែផ្ទុយមកវិញជនជាប់ចោទ បានប្តឹងទាស់នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ គឺក្រោយថ្ងៃជូនដំណឹងពីសាលដីកា ដល់ទៅជាង៧ ខែ ។ តំណាងអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច ៖

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៤៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted]សារី ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩១ ក្រIII (ឃ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៤៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របសជនជាប់ចោទ [redacted]សារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលសវនាការនេះ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី មិនបានចូលរួមតាមការកោះហៅរបស់មហាអយ្យការអមតុលាការកំពូលទេ ។ ប៉ុន្តែ ជនជាប់ចោទ បានលើកឡើងនូវមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួននៅក្នុងពាក្យបណ្តឹងសាទុក្ខ ហើយម្យ៉ាងទៀត ក្នុងរឿងក្តីនេះ តុលាការកំពូលពិនិត្យ និងពិចារណាតែលើការអនុវត្តខុសច្បាប់របស់តុលាការអង្គហេតុប៉ុណ្ណោះ ។ ដូច្នេះ តុលាការកំពូលអាចជំនុំជម្រះដោយមិនចាំបាច់មានវត្តមានរបស់ជនជាប់ចោទបាន ។

Scanned with CamScanner

៣-យល់ឃើញថា នៅក្នុងពាក្យបណ្ដឹងសាទុក្ខចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ជនជាប់ចោទ [redacted] សារី បានលើកឡើងថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ភ្នំពេញ មិនត្រឹមត្រូវទេ ដោយលើកមូលហេតុថា ខ្លួនមិនបានទទួលដំណឹងអំពីលិខិតជូនដំណឹងពីសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ នោះតុលាការកំពូលពិនិត្យមាត្រា៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំឡុងពេលដាក់ពាក្យបណ្ដឹងទាស់របស់ពិរុទ្ធជន១៥ថ្ងៃ គិតពីថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដពីសាលដីកាកំបាំងមុខ កាលណាសាលដីកាកំបាំងមុខនេះ មិនត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ក្នុងការជូនដំណឹងនេះ ជនជាប់ចោទ [redacted] សារី ត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ តាមលិខិតដោះលែងលេខ១០២ ព.គ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់ប្រធានពន្ធនាគារខេត្តព្រៃវែង ហើយត្រូវបានក្រឡាបញ្ជីសាលាឧទ្ធរណ៍ភ្នំពេញ ជូនដំណឹងអំពីសាលាដីកាកំបាំងមុខនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ទៅពិរុទ្ធជន [redacted] សារី ចំនួន៣លើក លើកទីមួយ ត្រូវបានលោកអនុសេនីយ៍ឯក [redacted] សំអូន ធ្វើចំណារបញ្ជាក់អំពីការបញ្ជូននេះនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៧ ថា ដោយឈ្មោះ [redacted] សារី មិនស្ថិតនៅលំនៅដ្ឋាននេះ លោកបានប្រគល់លិខិតជូនដំណឹងនេះឱ្យឈ្មោះ [redacted] សំអាត ជាកូនប្រសារទទួលជំនួសទុកឱ្យឈ្មោះ [redacted] សារី ហើយ ចំណារនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ របស់លោកអនុសេនីយ៍ឯក [redacted] សំអូន ថាលោកបានយកលិខិតជូនដំណឹងនេះទៅដល់ផ្ទះរបស់ [redacted] សារី តែឈ្មោះនេះមិននៅក្នុងមូលដ្ឋាននេះទេ ហើយប្រពន្ធឈ្មោះ [redacted] រីម បដិសេធមិនព្រមទទួលយកទេ និងចំណារចុងក្រោយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់លោកអនុសេនីយ៍ឯក [redacted] សំអូន ថាបានឱ្យដំណឹងពីសាលដីកាកំបាំងមុខនេះទៅពិរុទ្ធជន [redacted] សារី ដល់លំនៅឋាន តែមិននៅផ្ទះ បានទុកមួយច្បាប់នៅនឹងប្រពន្ធឈ្មោះ [redacted] រីម សម្រាប់ទុកជូនប្ដី [redacted] សារី មួយច្បាប់បិទនៅលំនៅឋានរបស់ [redacted] សារី និងមួយច្បាប់ទៀត បិទនៅសាលាឃុំ ប៉ុន្តែ ត្រូវបានជនជាប់ចោទ [redacted] សារី ដាក់ពាក្យបណ្ដឹងទាស់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ឃើញថា ការជូនដំណឹងពីសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ ត្រឹមត្រូវតាមច្បាប់ ហើយការមិនទទួលបានការជូនដំណឹងនេះ ជាកំហុសរបស់ជនជាប់ចោទខ្លួនឯងដែលត្រូវមានកាតព្វកិច្ចជូនដំណឹងអំពីការផ្លាស់ប្ដូរលំនៅឋានរបស់ខ្លួនមកសាលាឧទ្ធរណ៍ ឃើញថា បណ្ដឹងទាស់របស់ជនជាប់ចោទហួសកំណត់ច្បាប់ហើយ ហើយមូលហេតុនៃបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ មិនត្រឹមត្រូវតាមការកំណត់មាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩៩ ក្រ.VI.បស ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធ បណ្ដឹងសាទុក្ខលេខ៤៤៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទ [redacted] សារី ។

Scanned with CamScanner

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៨៩ ក្រ.VI.បស ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល ។

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner